**Declassified to Public**
**12 June 2020**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 29 / 08 / 2016
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស/ខ្មែរ [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ឯកសារពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចូលក្នុងសំណុំរឿង ០០៤

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្យ
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីយឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ")បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយស្នើសុំឱ្យស៊ើបអង្កេតការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រនៅក្នុងសំណុំរឿង ០០៤ ("ដីកាសន្និដ្ឋានបន្ថែម")[1]។

៣. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទនានា រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើអមនុស្សធម៌ផ្សេងទៀត ជាពិសេសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ[2]។

៤. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានដាក់ យឹម ទិត្យ ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទនានា រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើអមនុស្សធម៌ផ្សេងទៀត ជាពិសេសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកសំឡូត តំបន់ ១ និងនៅឃុំកំពង់ព្រៀង និងឃុំវាំងកេសី តំបន់ ៤ ភូមិភាគពាយ័ព្យ[3]។

៥. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ស.ព.អ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់ឯកសារពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រចូលក្នុងសំណុំរឿង ០០៤("សំណើ")[4]។

---

[1]សំណុំរឿង០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

[2]សំណុំរឿង០០៤ ឯកសារ D303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀត* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១២-១៣។

[3]សំណុំរឿង០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ១៤ និង ១៦-១៧។

[4]សំណុំរឿង០០៤ ឯកសារ D310 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់ឯកសារស្តីអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ និងអាពាហ៍ពិពាហ៍ដោយបង្ខំចូលក្នុងសំណុំរឿង ០០៤* ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

01323151



## II. សារណា

៦. ស.ព.អ ស្នើថា ស.ច.ស គួរដាក់ចូលក្នុងសំណុំរឿង ០០៤ នូវឯកសារចំនួន ១០ និងវីដេអូចំនួនបីពីសំណុំរឿង ០០២ និងវីដេអូមួយដែលមាននៅក្នុង YouTube ("ឯកសារដែលបានស្នើសុំ") ដែលគាត់អះអាងថាពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរៀបអាពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ[5]។

៧. នៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងសំណើ ស.ព.អ បានបង្ហាញបញ្ជីឯកសារដែលបានស្នើសុំ និងភាពពាក់ព័ន្ធជាក់លាក់នៃឯកសារទាំងនោះ[6]។

៨. ស.ព.អ ទទួលស្គាល់ថា មានឯកសារជាន់គ្នាខ្លះជាមួយនឹងឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ០០៤ ប៉ុន្តែ ស.ព.អ អះអាងថា ឯកសារដែលបានស្នើសុំ បង្ហាញខ្លឹមសារច្បាស់ជាងអំពីហេតុការណ៍ស្រដៀងគ្នាមួយចំនួនដែលបានកើតឡើងនៅទូទាំងប្រទេស គឺពាក់ព័ន្ធនឹងការបញ្ជាក់អំពីគំរូ និងភស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តដោយសារឧក្រិដ្ឋកម្មទាំងនោះ[7]។

## III. ពិភាក្សា

### ក. ភាពច្បាស់លាស់នៃកិច្ចស៊ើបសួរដែលបានស្នើសុំ

៩. សំណើ បានបង្ហាញយ៉ាងច្បាស់លាស់គ្រប់គ្រាន់អំពីកិច្ចស៊ើបសួរដែលបានស្នើសុំ ជាពិសេសនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសំណើ គឺបានបង្ហាញ និងរៀបរាប់អំពីឯកសារ និងវីដេអូនីមួយៗដែលត្រូវដាក់ចូលក្នុងសំណុំរឿង ០០៤[8]។

---

[5] សំណើ កថាខណ្ឌ ១, ១០ និង ១១-១៣។

[6] សំណុំរឿង០០៤ ឯកសារ D310.2 *ឧបសម្ព័ន្ធ ក* ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦។

[7] សំណើ កថាខណ្ឌ ១២។

[8] សំណើ ឧបសម្ព័ន្ធ ក *ឯកសារ និងវីដេអូពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានស្នើឱ្យដាក់ចូលក្នុងសំណុំរឿង ០០៤*។

01323152



### ខ. ភាពពាក់ព័ន្ធជាបឋមនៃឯកសារ និងវីដេអូដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក

១០. សំណើ ផ្ដល់មូលហេតុបានគ្រប់គ្រាន់ដែលថា ឯកសារដែលបានស្នើសុំ គឺពាក់ព័ន្ធនឹង អោ អាន និង យឹម ទិត្យ ចំពោះការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយក៏ជួយបញ្ជាក់អំពីការពិត[9]។

១១. ការដាក់ឯកសារដែលបានស្នើសុំចូលក្នុងសំណុំរឿង នឹងមិនពន្យារកិច្ចស៊ើបសួរឡើយ ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទនៅក្នុងសំណុំរឿង ០០៤ ដែរ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១២. **អនុញ្ញាតតាម** សំណើ។

១៣. **បង្គាប់** ក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវដាក់ចូលក្នុងសំណុំរឿង ០០៤ នូវឯកសារ និងវីដេអូដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

[9]សំណើ កថាខណ្ឌ ១១ ដល់ ១៣។